ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការសហប្រជាជាតិ សូមសំដែងការគួរសមជូនចំពោះស្ថានបេសកកម្មអចិន្ត្រៃយ៍នៃបណ្តាប្រទេសទាំងអស់ប្រចាំអង្គការសហប្រជាជាតិ និងមានកិត្តិយសសូមយោងដល់កិច្ចពិភាក្សាស្តីពីបញ្ហាអ្វីដែលគេហៅថា "ការធ្លាក់ចុះនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា" រៀបចំរួមគ្នាដោយស្ថានបេសកកម្មអចិន្ត្រៃយ៍របស់សហរដ្ឋអាមេរិក និងគណៈប្រតិភូសហភាពអឺរ៉ុបប្រចាំអង្គការសហប្រជាជាតិ នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១៧ នៅស្ថានបេសកកម្មអចិន្ត្រៃយ៍សហរដ្ឋអាមេរិកប្រចាំអង្គការសហប្រជាជាតិ។

ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការតវ៉ាយ៉ាងខ្លាំងក្លាប្រឆាំងនឹងការពិភាក្សាបែបនេះដែលត្រូវបានរៀបចំឡើងក្នុងហេតុផលនយោបាយ និងមានចេតនាយ៉ាងច្បាស់ក្នុងការបំភាន់សាធារណៈមតិអន្តរជាតិ។ ស្ថានបេសកកម្មចាត់ទុកអាកប្បកិរិយាដ៏ក្រអឺតក្រទម និងគ្មានការគោរពបែបនេះ ជាការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជាយ៉ាងធ្ងន់ធ្ងរ ដែលផ្ទុយនឹងគោលការណ៍នៃការគោរពអធិបតេយ្យភាព និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងប្រទេសដទៃ ដូចមានចែងក្នុងមាត្រា២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

ដោយសារវេទិកាខាងលើនេះ មានគោលបំណងផ្តល់ព័ត៌មានមិនពិត និងបង្កការយល់ច្រឡំអំពីស្ថានភាពជាក់ស្តែងនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការសហប្រជាជាតិត្រូវបង្ខំចិត្តផ្តល់នូវការពន្យល់ទាំងអង្គហេតុ និងអង្គច្បាប់ សម្រាប់ជាព័ត៌មានជូនដល់គ្រប់ស្ថានបេសកកម្មទាំងអស់ដូចខាងក្រោម៖

១. ពឹតជាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងពីករណី កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយ ត្រូវបានចោទប្រកាន់ពីបទក្បត់ជាតិ និងឃុបឃិតជាមួយបរទេសដើម្បីផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់នៅកម្ពុជា ដោយអនុលោមតាមច្បាប់ជាធរមាន ។ នៅក្នុងវីដេអូដែលបានថតទុក កឹម សុខា បាននិយាយអួតអាងដោយខ្លួនឯងផ្ទាល់ជាចំហរ ទៅកាន់សហគមន៍ខ្មែរនៅប្រទេសអូស្ត្រាលីថា គាត់បានទទួលការបង្ហាត់បង្រៀនដោយប្រទេសមហាអំណាចមួយ ដើម្បីផ្តួលរំលំរដ្ឋាភិបាលកម្ពុជាដែលកើតចេញពីការបោះឆ្នោតតាមការប្រើប្រាស់វិធីញុះញង់ប្រជាជនឲ្យបង្កអំពើហិង្សា តាមគំរូព្រឹត្តិការណ៍នៅប្រទេសយូហ្គោស្លាវី និងស៊ែប៊ីដែលប្រការនេះជាការបង្ហាញឲ្យឃើញថា គាត់គោរពនិងស្តាប់តាមការបង្គាប់បញ្ជាទាំងស្រុងរពីមហាអំណាចនេះ។ ជាលទ្ធផល សមាជិកអតីតគណបក្សសង្គ្រោះជាតិចំនួន១១៨នាក់ ត្រូវបានហាមឃាត់មិនឲ្យធ្វើនយោបាយរយៈពេល៥ឆ្នាំដោយជាប់ពាក់ព័ន្ធនឹងការឃុបឃិតដូចគ្នានេះដែរ។ សូមបញ្ជាក់ថា នីតិរដ្ឋគឺជាផ្នែក

មួយដ៏សំខាន់ និងចាំបាច់សម្រាប់លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងអភិបាលកិច្ចល្អ។ ប៉ុន្តែជាអកុសល រាជរដ្ឋាភិបាលកម្ពុជាត្រូវបានទទួលការរិះគន់ដោយអយុត្តិធម៌ និងដោយមានការរើសអើងចំពោះការអនុវត្តវិធានការតាមផ្លូវច្បាប់ដើម្បីការពារឯករាជ្យភាព អធិបតេយ្យភាព និងសន្តិសុខរបស់ខ្លួន ខណៈពេលដែលបញ្ហាសន្តិសុខជាតិបែបនេះ មានភាពរសើបខ្លាំងបំផុតសម្រាប់ប្រទេសទាំងអស់ដែលជាសមាជិករបស់អង្គការសហប្រជាជាតិ។

២. រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលរងការចោទប្រកាន់ដោយអយុត្តិធម៌ផងដែរ ពីការរឹតបន្តឹងសេរីភាពក្នុងការបញ្ចេញមតិ ដោយសារការបិទសារព័ត៌មានមួយចំនួនតូច ក្នុងខណៈពេលដែលបច្ចុប្បន្ននេះ កម្ពុជាមានសារព័ត៌មានបោះពុម្ពផ្សាយចំនួន៨០០ សារព័ត៌មានចេញផ្សាយលើអ៊ីនធឺណិតចំនួន៧០ ទូរទស្សន៍ចំនួន ២២ ស្ថានីយ៍វិទ្យុចំនួន៣៣០ស្ថានីយ៍ និងសមាគមអ្នកកាសែតចំនួន៣៨។ ការផ្សាយរបស់វិទ្យុនិងទូរទស្សន៍បរទេសទាំងអស់ រួមទាំងវីអូអេ (VOA) និងអាស៊ីសេរី (RFA) គឺអាចចូលទស្សនានិងស្តាប់ដោយសេរី មិនមានការត្រួតពិនិត្យអ្វីទាំងអស់។

៣. វិធានការផ្លូវច្បាប់ដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់យកប្រឆាំងនឹងបុគ្គល អង្គការមិនមែនរដ្ឋាភិបាល(NGO) និងស្ថាប័នសារព័ត៌មានដែលរំលោភបំពានច្បាប់មួយចំនួនតូច មិនគួរត្រូវបានបកស្រាយថាជាការប៉ុនប៉ងបំផ្លាញលទ្ធិប្រជាធិបតេយ្យនៅកម្ពុជានោះទេ។ ហេតុការណ៍ពិតជាប្រវត្តិសាស្ត្របានបង្ហាញថា ការជ្រៀតជ្រែកពីបរទេសតែងតែបានបង្កឲ្យមានផលវិបាកខ្ទេចខ្ទាំដូចជាករណីប្រទេសកម្ពុជា និងប្រទេសជាច្រើនផ្សេងទៀត។ បទពិសោធន៍ដ៏ជូរចត់នៃសង្គ្រាមនិងអំពើប្រល័យពូជសាសន៍អស់រយៈពេលជិត៣ទសវត្សរ៍ បានបង្ខំឲ្យរាជរដ្ឋាភិបាលកម្ពុជាកំណត់ជាអាទិភាពចម្បងរបស់ខ្លួន គឺការថែរក្សាសន្តិភាព និងស្ថិរភាពដែលទទួលបានយ៉ាងលំបាក និងការពង្រឹងនីតិរដ្ឋដើម្បីធានាថាការអភិវឌ្ឍន៍ជាតិដ៏ឆាប់រហ័សរបស់យើងនឹងបន្តទៅមុខដោយមិនមានភាពរាំងស្ទះ។

៤. បច្ចុប្បន្ននេះ មានគណបក្សនយោបាយប្រមាណ៣៥ បានចុះបញ្ជីចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ខាងមុខនេះ។ ដោយមានគណបក្សនយោបាយជាច្រើនកំពុងធ្វើសកម្មភាពនៅកម្ពុជា គេអាចមើលឃើញថាលំហលទ្ធិប្រជាធិបតេយ្យ និងប្រព័ន្ធពហុបក្សកំពុងចាក់ឫសយ៉ាងជ្រៅនៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តជាងពេលណាណាទាំងអស់ក្នុងការប្រកាន់លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ស្របតាមការកំណត់របស់រដ្ឋធម្មនុញ្ញកម្ពុជា និងរៀបចំការបោះឆ្នោតព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅថ្ងៃទី២៥ ខែកុម្ភៈ និងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ ដោយសេរី យុត្តិធម៌ និងមានរបៀបរៀបរយ ដែលអាចទទួលយកបានដោយគ្រប់ភាគីចូលរួមទាំងអស់។

ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា សូមឆ្លៀតឱកាសនេះ សំដែងសារជាថ្មីជូនចំពោះស្ថានបេសកកម្មអចិន្ត្រៃយ៍ទាំងអស់ប្រចាំអង្គការសហប្រជាជាតិ នូវការគោរពដ៏ខ្ពង់ខ្ពស់បំផុត។